*រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ (V1)*

# បទអន្តរាគមន៍

## របស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាល

*ថ្លែងក្នុងកិច្ចប្រជុំពេញអង្គលើកទី៧ នីតិកាលទី៦ នៃរដ្ឋសភា ពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ នៅវិមានរដ្ឋសភា*

- *សូមគោរព **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *សូមគោរព **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អនុប្រធានទី១** នៃរដ្ឋសភា ជាទីគោរព!*
- *សូមគោរព **លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី អនុប្រធានទី២** នៃរដ្ឋសភា ជាទីគោរព!*
- *សូមគោរព **គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា** ជាទីគោរព!*
- *សូមគោរព **សម្តេច ឯកឧត្តម លោកជំទាវ** ជាសមាជិក សមាជិកានៃរដ្ឋសភាដ៏ឧត្តុង្គឧត្តម!*

ថ្ងៃនេះ ដោយមានការអនុញ្ញាត និងការចាត់តាំងដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំបាទ ព្រមទាំងសហការី ក្នុងនាមជាតំណាងរាជរដ្ឋាភិបាលការពារ "សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី(មួយ), មាត្រា៨៩, មាត្រា៩៨ ថ្មី, មាត្រា១០២ ថ្មី, មាត្រា១១៩ ថ្មី(មួយ) និងមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ" ដែលតទៅនេះយើងហៅកាត់ថា "វិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា" សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ដែលបានសម្រេចដាក់សេចក្តីព្រាងច្បាប់ធម្មនុញ្ញនេះចូលក្នុងរបៀបវារៈនៃសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៦ នៃរដ្ឋសភា នាពេលនេះ។

ខ្ញុំសូមឆ្លៀតឱកាសដ៏បវរនេះ ថ្លែងអំណរគុណចំពោះ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ម៉ែន បញ្ញា ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា**, ឯកឧត្តម លោកជំទាវ ជាអនុប្រធាន

និងសមាជិកទាំងអស់នៃគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា ព្រមទាំង ឯកឧត្តម និង លោកជំទាវ ជាប្រធាន និងជាតំណាងគណៈកម្មការនានានៃរដ្ឋសភា ដែលបានជួយពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ធម្មនុញ្ញនេះ ប្រកបដោយការយកចិត្តទុកដាក់ និងស្មារតីទទួលខុសត្រូវខ្ពស់។ ខ្ញុំសូមឯកភាពជាមួយខ្លឹមសារនៃរបាយការណ៍ដែលបានលើកឡើងមុននេះបន្តិចដោយ **ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ម៉ែន ចញ្ញា ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា** ទាំងលើខ្លឹមសារនៃសេចក្តីព្រាងច្បាប់ធម្មនុញ្ញនេះ ទាំងលើដំណើរការនៃការរៀបចំសេចក្តីព្រាងច្បាប់ធម្មនុញ្ញ។

***សម្តេចមហាពញាចក្រី*** *ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

*សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា នៃរដ្ឋសភាដ៏ឧត្តុង្គឧត្តម!*

បន្តទៅទៀតនេះ, ខ្ញុំបាទសូមអនុញ្ញាតបង្ហាញជូនអង្គរដ្ឋសភាដ៏ឧត្តុង្គឧត្តមអំពីគោលបំណង, អំពីមូលដ្ឋានច្បាប់ និងអំពីខ្លឹមសារសំខាន់ៗនៃការធ្វើវិសោធនកម្មលើក១០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជា-ណាចក្រកម្ពុជា ដូចតទៅ៖

## *I-អំពីគោលបំណងនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០៖*

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ចំនួន ៩ លើក រួចមកហើយ ក្នុងគោលបំណងធានាឱ្យបាននូវនិរន្តរភាពជាតិ ក៏ដូចជាធានាការពារនូវឧត្តមប្រយោជន៍របស់ប្រទេសជាតិ និងប្រជាជនកម្ពុជា។ ចំពោះសំណើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញ នាពេលនេះ ក៏ត្រូវបានធ្វើឡើងក្នុងគោលបំណងសំខាន់ចំនួន ២ ផងដែរ ដើម្បីជាឧត្តមប្រយោជន៍ជាតិ គឺ៖ *(ទី១)*-ការធានាឱ្យស្ថាប័នកំពូលរបស់ជាតិ ជាពិសេស អំណាចនីតិប្រតិបត្តិដែលមានបេសកកម្មចម្បងក្នុងការដឹកនាំការងារទូទៅរបស់រដ្ឋ បានដំណើរការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយនិរន្តរភាព នៅគ្រប់កាលៈទេសៈ និង *(ទី២)*-ការធានាការពារ និងថែរក្សាឱ្យបាននូវសន្តិភាព, សន្តិសុខសង្គម, សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពនយោបាយរបស់ប្រទេសជាតិ នៅគ្រប់កាលៈទេសៈទាំងអស់ ដើម្បីជាគ្រឹះសម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ និងសេចក្តីសុខសាន្តរបស់ប្រជាជនកម្ពុជា។

ដើម្បីបម្រើឱ្យគោលបំណងដ៏សំខាន់របស់ប្រទេសជាតិទាំង ២ ខាងលើនេះ សំណើធ្វើវិសោធនកម្មលើកទី១០ នេះ មានការពាក់ព័ន្ធនឹងមាត្រាចំនួន ៨ មាត្រា ក្នុងនោះ៖ *រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ៦ មាត្រា* គឺមាត្រា១៩ ថ្មី(មួយ), មាត្រា៨៩, មាត្រា៩៨ ថ្មី, មាត្រា១០២ ថ្មី, មាត្រា ១១៩ ថ្មី(មួយ) និងមាត្រា១២៥ ថ្មី និង*ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ចំនួន ២ មាត្រា* គឺ មាត្រា៣ ថ្មី និង មាត្រា៤ ថ្មី។

*II-អំពីមូលដ្ឋានច្បាប់សម្រាប់ការធ្វើសំណើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ នេះ៖*

ដូចមានក្នុងសេចក្តីថ្លែងហេតុជូនរដ្ឋសភារួចហើយ និងលិខិតគោរពជូន **សម្តេចប្រធានរដ្ឋសភា**, សំណើធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញនេះ ត្រូវបានធ្វើឡើង ដោយផ្អែកលើមូលដ្ឋាននៃមាត្រា១៥៣ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា *"ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល"*។ ផ្អែកលើមូលដ្ឋាននៃមាត្រា១៥៣ ថ្មី(ពីរ) ខាងលើ, **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងនាមជា **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានផ្តួចផ្តើមធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញនេះ និងបានដាក់សេចក្តីព្រាងវិសោធនកម្មនេះ ឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២ កន្លងទៅនេះ។ ទន្ទឹមនេះ, និងស្របតាមមាត្រា១៤៣ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក៏បានក្រាបបង្គំទូលថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** នូវអត្ថបទនៃសេចក្តីព្រាងច្បាប់ធម្មនុញ្ញនេះ តាមលិខិតលេខ ៦២៥ លស ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២ ដើម្បី **ព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់មានព្រះរាជតម្រិះពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ។ **ព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់បានផ្ញើព្រះរាជសារតបវិញ តាម **ព្រះរាជសារចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២** ដោយភ្ជាប់នូវ**លិខិតលេខ ០៦៤/០១/២០២២ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ របស់ក្រុមប្រឹក្សាធម្មនុញ្ញ** ដោយក្រុមប្រឹក្សាធម្មនុញ្ញ បានថ្វាយមតិដែលមានខ្លឹមសារសំខាន់ថា សំណើធ្វើវិសោធនកម្មលើកទី១០ នេះ អាចធ្វើទៅបាន គឺស្របតាមបរិបទនៃសភាពការណ៍ជាក់ស្តែង និងពុំមានអ្វីប៉ះពាល់ដល់ *ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស* និង *របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ* ព្រមទាំង *ធ្វើឡើងក្នុងពេលដែលប្រទេសជាតិមិនឋិតក្នុងភាពអាសន្ន* ឡើយ។

សំណើធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញនាពេលនេះ គឺធ្វើឡើងត្រឹមត្រូវស្របតាមគោលការណ៍ និងនីតិវិធីដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេស មាត្រា១៤៣ ថ្មី និងជំពូកទី១៦ ថ្មី(ពីរ) ចាប់ពីមាត្រា១៥២ ថ្មី ដល់មាត្រា១៥៥ ថ្មី។

*III-អំពីខ្លឹមសារសំខាន់ៗនៃការធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញ៖* ខ្លឹមសារសំខាន់ៗ ចំពោះសំណើសុំធ្វើវិសោធនកម្មលើកទី១០ នេះ មានដូចតទៅ៖

*<u>ទី១-ការស្នើធ្វើវិសោធនកម្មមាត្រា១៩ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ៖</u>* មាត្រា១៩ ថ្មី(មួយ) នេះ ចែងទាក់ទងនឹងការតែងតាំងនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីដោយព្រះមហាក្សត្រ។ ការធ្វើវិសោធនកម្មមាត្រា១៩ ថ្មី(មួយ) គឺដោយសារមាត្រា១៩ ថ្មី(មួយ) នេះ បានយោងនៅក្នុងបទប្បញ្ញត្តិខ្លួន ទៅមាត្រា១១៩ ថ្មី(មួយ) ហើយដែលមាត្រា១១៩ ថ្មី(មួយ) នេះ ត្រូវធ្វើវិសោធនកម្មលើកនេះ ទៅជាមាត្រា១១៩ ថ្មី(ពីរ)។ ដូចនេះ, វាជាការចាំបាច់ខាងផ្នែកទម្រង់ ដែលមាត្រា១៩ ថ្មី(មួយ) ត្រូវបានស្នើធ្វើវិសោធនកម្ម ដូរខ្លឹមសារមាត្រាយោង ដើម្បីធានាបាននូវសង្គតិភាពជាមួយការធ្វើវិសោធនកម្មមាត្រា១១៩ ថ្មី(មួយ) ទៅជាមាត្រា១១៩ ថ្មី(ពីរ)។

*<u>ទី២-ការស្នើធ្វើវិសោធនកម្មមាត្រា៨៩ នៃរដ្ឋធម្មនុញ្ញ៖</u>* មាត្រា៨៩ នេះ ចែងទាក់ទងនឹងការអញ្ជើញឥស្សរជនដ៏ឧត្តមណាមួយ ដើម្បីមកបំភ្លឺរដ្ឋសភា។ យោងតាមមាត្រា៨៩ បច្ចុប្បន្ន តាមការស្នើសុំពីសមាជិកចំនួនមួយភាគដប់ យ៉ាងតិច, រដ្ឋសភាអាចអញ្ជើញ **“ឥស្សរជនដ៏ឧត្តមណាមួយ”** មកបំភ្លឺរដ្ឋសភាអំពីបញ្ហាដែលមានសារសំខាន់ពិសេស។ ពាក្យថា **“ឥស្សរជនដ៏ឧត្តមណាមួយ”** នៅទីនេះ គឺមិនមានភាពច្បាស់លាស់នោះទេ ហើយអាចយកទៅបកស្រាយបានច្រើនយ៉ាង ដែលអាចធ្វើឱ្យប៉ះពាល់ដល់គោលការណ៍គ្រឹះនៃការបែងចែកអំណាចដាច់ពីគ្នា ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ គឺអំណាចនីតិប្បញ្ញត្តិ, អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ម្យ៉ាងទៀត ជាគោលការណ៍ក្នុងរបបសភានិយម, រាជរដ្ឋាភិបាល ដែលជាអង្គការនីតិប្រតិបត្តិ គឺជាស្ថាប័ន ដែលត្រូវមានការទទួលខុសត្រូវចំពោះមុខរដ្ឋសភា។ ផ្អែកលើគោលការណ៍ទាំងនេះ, មាត្រា៨៩ នៃរដ្ឋធម្មនុញ្ញ ត្រូវបានស្នើធ្វើវិសោធនកម្ម ដោយកំណត់ឱ្យរាជរដ្ឋាភិបាលត្រូវមានការទទួលខុសត្រូវចំពោះមុខរដ្ឋសភា នៅគ្រប់កាលៈទេសៈ ដោយរួមទាំងការបំភ្លឺលើបញ្ហាបច្ចេកទេស ឬជំនាញអ្វីមួយ។

*<u>ទី៣-ការស្នើធ្វើវិសោធនកម្មមាត្រា៩៨ ថ្មី នៃរដ្ឋធម្មនុញ្ញ៖</u>* មាត្រា៩៨ ថ្មី ចែងថា៖ *“រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ញត្តិបន្ទោសរាជរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន។”* មាត្រា៩៨ ថ្មី នេះ ត្រូវបានស្នើធ្វើវិសោធនកម្មដើម្បីកែសម្រួលដោយផ្អែកលើហេតុផលចំនួន ២ ដូចតទៅ ៖

*<u>(១)-ដើម្បីបំពេញចន្លោះខ្វះខាតនៃបទប្បញ្ញត្តិនៃមាត្រា៩៨ ថ្មី៖</u>* មាត្រា៩៨ ថ្មី បច្ចុប្បន្ន មិនបានចែងកំណត់ថា នៅពេលដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីមុខតំណែងដោយការអនុម័តញត្តិបន្ទោសដោយរដ្ឋសភា, តើការដឹកនាំអំណាចនីតិប្រតិបត្តិត្រូវធ្វើដូចម្តេច ចាប់ពីពេលដែលរាជ-

រដ្ឋាភិបាល ត្រូវបានទម្លាក់ពីមុខតំណែង រហូតដល់ពេលដែលរាជរដ្ឋាភិបាលថ្មីត្រូវបានបង្កើត។ ប្រការដែលរដ្ឋធម្មនុញ្ញ ពុំបានកំណត់ត្រង់ចំណុចនេះ នឹងបង្កើតឱ្យមានស្ថានភាពមួយ ហៅថា "*សុញ្ញភាពនៃអំណាច*" ដែលអាចបង្កជាហានិភ័យនាំទៅដល់អស្ថិរភាពនយោបាយ។ ក្នុងន័យនេះ ការស្នើធ្វើវិសោធនកម្មមាត្រា៩៨ ថ្មី នាពេលនេះ គឺដើម្បីបំពេញមាត្រា៩៨ ថ្មី ដោយបន្ថែមខ្លឹមសារដូចតទៅ៖ *"ក្នុងករណីដែលរាជរដ្ឋាភិបាល ត្រូវបានទម្លាក់ពីមុខតំណែងដោយរដ្ឋសភា រាជរដ្ឋាភិបាលដែលត្រូវចេញពីមុខតំណែងនេះមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។"*

*(២)-ដើម្បីធានានូវសង្គតិភាពរវាងមាត្រា៩៨ ថ្មី និងមាត្រាដទៃទៀតនៃរដ្ឋធម្មនុញ្ញ៖* យោងតាម មាត្រា៩៨ ថ្មី នៃរដ្ឋធម្មនុញ្ញ, រដ្ឋសភាត្រូវការសម្លេង ៣០ នាក់ ដើម្បីធ្វើញត្តិបន្ទោសដាក់ជូនរដ្ឋសភា។ ប៉ុន្តែ ការកំណត់យកចំនួនសមាជិករដ្ឋសភាចំនួន ៣០ នាក់ ដើម្បីធ្វើញត្តិបន្ទោស គឺពុំមានមូលដ្ឋានរឹងមាំត្រង់ចំណុចណាមួយនៅក្នុងរដ្ឋធម្មនុញ្ញឡើយ។ ដូចនេះ មាត្រា៩៨ ថ្មី នៃរដ្ឋធម្មនុញ្ញត្រូវបានស្នើធ្វើវិសោធនកម្ម ដោយកំណត់យកចំនួន ១/៣ នៃចំនួនសមាជិករដ្ឋសភាទាំងមូល ដើម្បីធ្វើញត្តិបន្ទោស សំដៅធានាឱ្យបាននូវសង្គតិភាព និងភាពរលូនជាមួយបទប្បញ្ញត្តិផ្សេងទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដូចជា មាត្រា៨៣ ទាក់ទងនឹងការកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ និងមាត្រា១០៧ ថ្មី ទាក់ទងនឹងការកោះប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ព្រោះការធ្វើញត្តិបន្ទោសទម្លាក់រាជរដ្ឋាភិបាល ដែលជាកិច្ចការសំខាន់របស់រដ្ឋសភាស្របតាមគោលការណ៍ប្រជាធិបតេយ្យតាមបែបសភានិយម ក៏ត្រូវអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងដោយអាចត្រូវផ្សារភ្ជាប់នឹងនីតិវិធីនៃការកោះប្រជុំរដ្ឋសភាជាវិសាមញ្ញផងដែរ។ បន្ថែមពីនេះ ការកែសម្រួលចំនួននៃសមាជិករដ្ឋសភាពី ៣០ នាក់ ទៅចំនួន ១/៣ នៃចំនួន សមាជិករដ្ឋសភាទាំងមូល ក៏ត្រូវបានធ្វើឡើង *ម្យ៉ាង* ដើម្បីធានាឱ្យអំណាចនីតិប្រតិបត្តិអាចមានដំណើរការប្រព្រឹត្តទៅ ដោយរលូនក្នុងការដឹកនាំកិច្ចការទូទៅរបស់រដ្ឋប្រកបដោយការទទួលខុសត្រូវ ហើយ *ម្យ៉ាងទៀត* ដើម្បីបង្ហាញអំពីការទទួលខុសត្រូវខ្ពស់របស់រដ្ឋសភាក្នុងការដំណើរការនីតិវិធីនៃការធ្វើញត្តិបន្ទោស ជាពិសេស របៀបវារៈដ៏សំខាន់ទាក់ទងនឹងការអនុម័តញត្តិបន្ទោសដើម្បីទម្លាក់សមាជិករាជរដ្ឋាភិបាល ឬទម្លាក់រាជរដ្ឋាភិបាល ដោយប្រើសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។

*ទី៤-ការស្នើធ្វើវិសោធនកម្មមាត្រា១០២ ថ្មី នៃរដ្ឋធម្មនុញ្ញ៖* មាត្រា១០២ ថ្មី បានចែងអំពីសមត្ថកិច្ចរបស់ព្រឹទ្ធសភាក្នុងការសម្រេចបញ្ចប់កាលៈទេសៈពិសេស ដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលសមត្ថកិច្ចនេះដូចគ្នា ឬជាន់គ្នាទៅនឹងសមត្ថកិច្ចរបស់រដ្ឋសភា ដែលមានចែងក្នុង

មាត្រា៨៦ នៃរដ្ឋធម្មនុញ្ញ។ ស្ថានភាពនេះ បានបង្កើតជាភាពមិនច្បាស់លាស់អំពីសមត្ថកិច្ចក្នុងការសម្រេចបញ្ចប់ការដាក់ប្រទេសជាតិក្នុងភាពអាសន្ន ហើយក៏អាចបង្កជាការលំបាកខាងផ្លូវច្បាប់ប្រសិនបើមានការសម្រេចខ្វែងគ្នារវាងស្ថាប័នព្រឹទ្ធសភានិងស្ថាប័នរដ្ឋសភានេះ។

ដូច្នេះ ដើម្បីដោះស្រាយភាពមិនច្បាស់លាស់ខាងលើ ព្រមទាំងដើម្បីធានានូវសង្គតិភាពរវាងបទប្បញ្ញត្តិនានា ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ, មាត្រា១០២ ថ្មី នេះ ត្រូវបានស្នើធ្វើវិសោធនកម្មដើម្បីកែសម្រួលដោយកំណត់ឱ្យព្រឹទ្ធសភាសម្រេចរួមគ្នាជាមួយរដ្ឋសភា ក្នុងក្របខណ្ឌនៃសមាជរវាងរដ្ឋសភា និងព្រឹទ្ធសភា ក្នុងការបញ្ចប់កាលៈទេសៈពិសេសដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ហើយរក្សាសមត្ថកិច្ចទោលរបស់រដ្ឋសភាក្នុងការសម្រេចបញ្ចប់កាលៈទេសៈដាក់ប្រទេសជាតិក្នុងភាពអាសន្នដោយយោងតាមតម្រូវការចាំបាច់នៃកាលៈទេសៈពិសេស ស្របតាមមាត្រា៨៦ នៃរដ្ឋធម្មនុញ្ញ។

*ទី៥-ការស្នើធ្វើវិសោធនកម្មមាត្រា១១៩ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ៖* កថាខណ្ឌទី១ នៃមាត្រា ១១៩ ថ្មី(មួយ)នេះ ត្រូវបានស្នើធ្វើវិសោធនកម្ម ដោយមានខ្លឹមសារដូចតទៅ៖ *"តាមសេចក្ដីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងរូបជនមួយរូបជានាយករដ្ឋមន្ត្រី ឱ្យបង្កើតរាជរដ្ឋាភិបាល។ សេចក្ដីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភានេះ ត្រូវចម្លងជូនប្រធានរដ្ឋសភា។ រូបជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់ និងដែល ត្រូវបានជ្រើសរើសចេញពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ រូបជនដែលត្រូវបានចាត់តាំង នេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភាដែលផ្ដល់ឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្ដីទុកចិត្តពីរដ្ឋសភា។ ការបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តនេះ ត្រូវធ្វើលើបញ្ជីសមាសភាពនៃគណៈរដ្ឋមន្ត្រីទាំងមូល។ កាលបើរដ្ឋសភា បានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។"*

បន្ថែមពីនេះ ការធ្វើវិសោធនកម្មមាត្រា១១៩ ថ្មី(មួយ) ក៏មានគោលបំណងដើម្បីធានាឱ្យបានច្បាស់លាស់អំពីនិរន្តរភាពនៃការដឹកនាំអំណាចនីតិប្រតិបត្តិពីនីតិកាលមួយ ទៅនីតិកាលមួយទៀតនៃរដ្ឋសភា។ ក្នុងន័យនេះ មាត្រា១១៩ ថ្មី(មួយ) ក៏ត្រូវបានចែងបន្ថែមនូវបទប្បញ្ញត្តិដែលកំណត់ថា៖ *"នៅពេលផុតនីតិកាលនីមួយៗរបស់រដ្ឋសភា រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែង មានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។"*

*ទី៦-ការស្នើធ្វើវិសោធនកម្មមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញ ទាក់ទងនឹងការរៀបចំចាំបាច់នានាក្នុងករណីតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ៖* មាត្រា១២៥ ថ្មី បច្ចុប្បន្ន ចែងថា *"បើតំណែង*

*នាយករដ្ឋមន្ត្រី នៅទំនេរជាស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី ក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ កាលបើការទំនេរនេះជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយក-រដ្ឋមន្ត្រីស្ដីទីជាបណ្ដោះអាសន្ន។"* មាត្រា១២៥ ថ្មី នេះ ពុំបានបញ្ជាក់ឱ្យបានច្បាស់លាស់ថា៖ *(ទី១)*-តើករណីណាខ្លះ ដែលតំណែង នាយករដ្ឋមន្ត្រី ត្រូវបានកំណត់ថា នៅទំនេរជាស្ថាពរ? *(ទី២)*-តើការលាលែងពីមុខតំណែងជានាយករដ្ឋមន្ត្រី ដែលត្រូវបានចាត់ទុក ជាទូទៅថា ជាស្ថានភាពមួយនៃស្ថានភាពទំនេរស្ថាពរនៃតំណែងនាយករដ្ឋមន្ត្រី ត្រូវអនុវត្តតាមនីតិវិធីបែបណា? ហើយ *(ទី៣)*-នៅពេលតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរនោះ តើការគ្រប់គ្រងអំណាចចាប់ពីពេលដែលតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ រហូតដល់គណៈរដ្ឋមន្ត្រីថ្មី ចូលកាន់តំណែង ត្រូវអនុវត្តដូចម្ដេច? ការចែងមិនច្បាស់លាស់ និងមិនគ្រប់ជ្រុងជ្រោយសម្រាប់ស្ថានភាពដែលតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ នឹងអាចមានហានិភ័យខ្ពស់ប៉ះពាល់ដល់និរន្តរភាពនៃអំណាចរបស់រដ្ឋាភិបាល។ មាត្រា១២៥ ថ្មី ត្រូវបានស្នើធ្វើវិសោធនកម្មដើម្បី បំពេញចន្លោះប្រហោងនៃរដ្ឋធម្មនុញ្ញ ក៏ដូចជារៀបចំឱ្យបានគ្រប់ជ្រុងជ្រោយឡើង ជាពិសេស ការកំណត់ឱ្យបានច្បាស់លាស់នូវចំណុចសំខាន់ៗយ៉ាងតិចចំនួន ៤ រួមមាន៖ (ទី១)-ការចាត់តាំងនាយករដ្ឋមន្ត្រីស្ដីទី ក្នុងករណីដែលនាយករដ្ឋមន្ត្រីអវត្តមានមួយកាលមួយគ្រា, (ទី២)-ការចែងអំពីមូលហេតុនានាដែលនាំឱ្យតំណែង នាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ជាអាទិ៍ អនិច្ចកម្ម, ការលាលែងពីមុខតំណែងរបស់នាយករដ្ឋមន្ត្រី ព្រមទាំងការចែងអំពីការចាត់ចែងចាំបាច់នានា ដើម្បីធានាដល់និរន្តរភាពនៃការដឹកនាំអំណាចនីតិប្រតិបត្តិ តាមរយៈការតែងតាំងគណៈរដ្ឋមន្ត្រីថ្មីឱ្យបានឆាប់រហ័ស, (ទី៣)-ការចែងអំពីបែបបទ នីតិវិធី និងការចាត់ចែងចាំបាច់នានាសម្រាប់ការលាលែងពីមុខតំណែងរបស់នាយករដ្ឋមន្ត្រី និង (ទី៤)-ការធានានិរន្តរភាពអំណាចរបស់រាជរដ្ឋាភិបាល ចាប់ពីពេលដែលតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ រហូតដល់គណៈរដ្ឋមន្ត្រីថ្មីចូលកាន់តំណែង ដែលជាគ្រឹះសម្រាប់ធានានិរន្តរភាព និងស្ថិរភាពរបស់ប្រទេសជាតិ។

*ទី៧-ការស្នើធ្វើវិសោធនកម្មមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ៖* មាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម ចែងទាក់ទងនឹងការបោះឆ្នោតជាកញ្ចប់ក្នុងការបង្កើតរាជរដ្ឋាភិបាល និងការរៀបចំក្បាលម៉ាស៊ីននៃរដ្ឋសភាក្នុងពេលតែមួយ នៅដើមនីតិកាលនៃរដ្ឋសភា។ ការស្នើធ្វើវិសោធនកម្មមាត្រាទាំងពីរមាត្រានេះ ធ្វើឡើង ម្យ៉ាង ដើម្បីធានាសង្គតិភាពផ្នែកទម្រង់ផង និងផ្នែកខ្លឹមសារផងជាមួយខ្លឹមសារនៃមាត្រានានាក្នុងរដ្ឋ-ធម្មនុញ្ញដែលត្រូវស្នើធ្វើវិសោធនកម្មលើកទី១០ នេះ និង ម្យ៉ាងទៀត ដើម្បីធានាថា ការបោះឆ្នោតជាកញ្ចប់តាមច្បាប់ធម្មនុញ្ញបន្ថែម អាចដំណើរការប្រព្រឹត្តទៅបាន នៅដើមនីតិកាលនីមួយៗនៃរដ្ឋសភា។

ការចែងបន្ថែមបទប្បញ្ញត្តិមួយចំនួនឱ្យបានច្បាស់លាស់ទាក់ទងនឹងឥស្សរជន ដែលជាព្រឹទ្ធសមាជិកនៃរដ្ឋសភា ដើម្បីធានាថា កិច្ចដំណើរការនៃការបោះឆ្នោតជាកញ្ចប់ដើម្បីបង្កើតក្បាលម៉ាស៊ីននៃរដ្ឋសភា និងរាជរដ្ឋាភិបាលក្នុងពេលតែមួយ នឹងពុំត្រូវបានរាំងស្ទះដោយប្រការណាមួយឡើយ ជាពិសេស ទាក់ទងនឹងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ព្រឹទ្ធសមាជិករដ្ឋសភានៅដើមនីតិកាលនីមួយៗនៃរដ្ឋសភា ទាក់ទងនឹង ការបោះឆ្នោតជាកញ្ចប់។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋសភាដ៏ឧត្តុង្គឧត្តម មេត្តាពិនិត្យ និងមេត្តាអនុម័ត *សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី(មួយ), មាត្រា៨៩, មាត្រា៩៨ ថ្មី, មាត្រា១០២ ថ្មី, មាត្រា១១៩ ថ្មី(មួយ) និងមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ* ជាការប្រញាប់ ដោយក្តីអនុគ្រោះ។

ម្យ៉ាងទៀត នាឱកាសនេះ ដើម្បីឆ្លើយតបនឹងកង្វល់របស់គណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ នេះ, ខ្ញុំបាទសូមគោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាពញាចក្រី** ប្រធានរដ្ឋសភា, **សម្តេចអគ្គ-មហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត អនុប្រធានទី១ នៃរដ្ឋសភា, លោកជំទាវកិត្តិសង្គហបណ្ឌិត អនុប្រធានទី២ នៃរដ្ឋសភា** ព្រមទាំង **សម្តេច ឯកឧត្តម លោកជំទាវ** ជាសមាជិក សមាជិកានៃរដ្ឋសភាដ៏ឧត្តុង្គឧត្តម មេត្តាអនុញ្ញាតជូន **ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** មានមតិមួយចំនួន។

*សូមអរគុណ!*